Dina

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤៣៧០ កសក

## ដីការអម

គោរពជូន: -ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង

| ល.រ | ឈ្មោះឯកសារ | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | -របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែមេសា ឆ្នាំ២០១៦** និងទិសដៅអនុវត្តបន្ត ............................. | ០១ច្បាប់ | "ដើម្បីជូនជ្រាប" --------- |

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៦

តប រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គលេខាធិការ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣)៧២៦ ១២៨ /៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## របាយការណ៍
## ស្តីពី
## សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## ប្រចាំខែឧសភា ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត

### I- សភាពការណ៍រួម

នៅក្នុងខែឧសភាឆ្នាំ២០១៦នេះ តាមការកត់សម្គាល់ឃើញថា មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយជាបង្គួរនៅតាមតំបន់មួយចំនួនក្នុងបណ្តារាជធានី ខេត្តទូទាំងប្រទេស បន្ទាប់ពីព្រះរាជពិធីច្រត់ព្រះនង្គ័លដែលជាសញ្ញាបង្ហាញថារដូវវស្សាបានឈានមកដល់ហើយ។ ប្រជាកសិករបានចាប់ផ្តើមបង្កបង្កើនផលស្រូវរដូវវស្សានៅតាមតំបន់ដែលមានទឹកគ្រប់គ្រាន់ ដោយសម្រេចបាន ៥,៣៤% (ស្ទូងនិងព្រោះស្មើនឹង១៣២ ១៧៨ហ.ត នៃផែនការ២ ៤៧៤ ៤៤៦ហ.ត តិចជាងឆ្នាំមុន ៩,២៧% បើប្រៀបធៀបរយៈពេលដូចគ្នា)។ ជារួម ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ មានការយឺតជាងឆ្នាំមុនប្រមាណ២៤២ ៨៤៥ហ.ត។ តែទោះជាយ៉ាងនេះក្តី ប្រជាកសិករបាននិងកំពុងខិតខំជំរុញការរៀបចំដីភ្ជួររាស់ សាប ព្រោះ និងដកស្ទូង ដើម្បីឱ្យទាន់រដូវកាលដាំដុះ ដោយអនុវត្តបច្ចេកទេសកសិកម្មសមស្រប។ ជាការកត់សម្គាល់ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មកំពុងមាននិន្នាការកើនឡើងដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវត្តន៍នៃយន្តូបនីយកម្មកសិកម្ម។ ជាក់ស្តែងក្នុងឆ្នាំ២០១៥ កន្លងមកនេះ ការភ្ជួររាស់ដោយគ្រឿងយន្តមានប្រមាណ៨៤ភាគរយ។ ក្រៅពីដំណាំស្រូវ ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម ក៏មានការកើនឡើងដែរបើប្រៀបធៀបនឹងឆ្នាំមុន។ សកម្មភាពគួរកត់សម្គាល់មួយទៀត គឺមន្ត្រីជំនាញរដ្ឋបាលព្រៃឈើបានបន្តកិច្ចសហការជាមួយគណៈកម្មការជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ចុះប្រតិបត្តិការត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនៅតាមអធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤ តាមស្មារតីនៃសេចក្តីសម្រេច លេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍនវិស័យកសិកម្ម២០១៤-២០១៨ដែលសម្រេចបានសម្រាប់ខែឧសភា ឆ្នាំ២០១៦នេះ មានដូចខាងក្រោម៖

### II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

#### ១ ផ្នែកដាំដុះ

##### ១.១ ផលិតកម្មដំណាំស្រូវ

នៅក្នុងខែឧសភាឆ្នាំ២០១៦នេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយជាបង្គួរនៅតាមតំបន់មួយចំនួនក្នុងបណ្តារាជធានី ខេត្តទូទាំងប្រទេស។ ចំពោះសភាពការណ៍នៃល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ មានលម្អិតដូចខាងក្រោម៖


អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

▪ ការងារបង្កបង្កើនផលស្រូវវស្សាឆ្នាំ២០១៦

○ ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន៣០៩ ០០៤ហ.ត ក្នុងនោះភ្ជួររាស់ដោយគោក្របីមាន៣ ២២៧ហ.ត និងដោយគ្រឿងយន្តមានចំនួន៣០៥ ៧៧៧ហ.ត តិចជាងឆ្នាំមុន៣៣៦ ៣៤៩ហ.ត

○ ផ្ទៃដីសាបសម្រេចបានចំនួន១៦២ហ.ត តិចជាងឆ្នាំមុនចំនួន១ ៥៣៧ហ.ត

○ ផ្ទៃដីសន្ទូងនិងពង្រោះសម្រេចបានចំនួន១៣២ ១៧៨ហ.ត ស្មើនឹង៥,៣៤% នៃផែនការ២ ៤៧៤ ៤៤៦ហ.ត តិចជាងឆ្នាំមុនចំនួន២៤២ ៨៤៥ហ.តនឹងស្រូវតាមប្រភេទរួមមាន៖

-ស្រូវស្រាលចំនួន៦០ ០៤៦ហ.ត តិចជាងឆ្នាំមុន៨០ ២៣៩ហ.ត

-ស្រូវកណ្តាលចំនួន២៥ ៥៧៩ហ.ត តិចជាងឆ្នាំមុន៧៨ ៥៣៧ហ.ត

-ស្រូវធ្ងន់ចំនួន៤០ ៨៧៧ហ.ត តិចជាងឆ្នាំមុន៥៤ ០៧៧ហ.ត

-ស្រូវចម្ការចំនួន២ ១៤១ហ.ត តិចជាងឆ្នាំមុន២ ២៨៤ហ.ត

-ស្រូវឡើងទឹកចំនួន៣ ៥៣៥ហ.ត តិចជាងឆ្នាំមុនចំនួន២៧ ៧០៨ហ.ត។

### ១.២ ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន១៤១ ០៥៧ហ.ត តិចជាងឆ្នាំមុនចំនួន១៨៨ ៣៤២ហ.ត ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន១២៩ ០៣៨ហ.ត ស្មើនឹង២០,៩៤% នៃផែនការ៦១៦ ១២៣ហ.ត តិចជាងឆ្នាំមុន១៨៣ ១១៤ហ.ត

- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន១២ ០១៩ហ.ត ស្មើនឹង៨,៧៦% នៃផែនការ១៣៧ ២៣៨ហ.ត តិចជាងឆ្នាំមុន៥ ២២៨ហ.ត។

ជាការកត់សម្គាល់ឃើញថា ផ្ទៃដីផលិតកម្មមានការថយចុះ ដែលឆ្លុះបញ្ចាំងពីការប្រែប្រួលនៅក្នុងប្រព័ន្ធផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម ដោយសារកត្តាធម្មជាតិ។

### ១.៣ ការនាំចេញអង្ករ

ការនាំចេញអង្ករកម្ពុជារយៈពេល៥ខែដើមឆ្នាំ២០១៦នេះ មានបរិមាណចំនួន២៣៤ ៣២៨តោនដែលមានការថយចុះចំនួន៨ ៦៩៧តោន (-៣,៧%) តិចជាងបរិមាណនាំចេញរយៈពេល៥ខែដើមឆ្នាំ២០១៥ ដែលមាន ២៤៣ ០២៥តោន។ ក្នុងនោះបរិមាណនាំចេញក្នុងខែឧសភានេះមានចំនួន៣២ ៥៥៨តោន ដែលមានការថយចុះ៩ ២៨៤តោន (-២៨,៥%) តិចជាងខែឧសភា ឆ្នាំ២០១៥ និងបាននាំចេញទៅកាន់ទិសដៅចំនួន៥១ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១ (៤៦ ៣៩២តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៣១ ៨៧២តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (២៩ ២០៤តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ (១២ ៥៣០តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥ (១២ ៤៣៩តោន) ប្រទេសបែលហ្ស៊ិកឈរលំដាប់ទី៦ (១២ ០២៤តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៧ (១០ ៥៤៤តោន) ប្រទេសឆេកឈរលំដាប់ទី៨ (១០ ០៥៣តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៩ (៨ ៩៥៨តោន) និង ប្រទេសហុងគ្រីឈរលំដាប់ទី១០ (៨ ២២៦តោន)។

## ២ ផ្នែកកៅស៊ូ

បច្ចុប្បន្ននេះតម្លៃកៅស៊ូមាននិន្នាការងើបឡើងបន្តិចវិញ ប៉ុន្តែទោះជាយ៉ាងណាក្រោមកិច្ចសហការជាមួយសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ដែលបង្កើតឡើងដោយរដ្ឋាភិបាលនៃប្រទេសទាំង១១ រួមទាំងកម្ពុជាផង យើងសង្ឃឹមថាតម្លៃកៅស៊ូអាចនឹងកើនឡើងវិញ តាមរយៈការរិះរកវិធានការនានាប្រកបដោយស្ថិរភាព និងមាននិរន្តរភាពសម្រាប់ជាប្រយោជន៍ដល់អ្នកដាំកៅស៊ូ។ បន្ថែមលើនេះទៀតនោះ រាជរដ្ឋាភិបាលក៏បានសម្រេចចេញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូរួចហើយ។ ដោយឡែក សម្រាប់ខែឧសភា ឆ្នាំ២០១៦នេះ តម្លៃកៅស៊ូជាមធ្យមក្នុងរង្វង់១ ២០០ទៅ១ ២៥០ ដុល្លារក្នុងមួយតោន។

## ៣ ផ្នែកផលិតកម្មនិងបសុពេទ្យបាល

**៣.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត រៀបចំឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្តនិងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- **ការងារកែលម្អពូជនិងចំណីសត្វ៖** ប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័សធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់ ដោយសហការជាមួយដៃគូពាក់ព័ន្ធនឹងវិស័យឯកជនផងដែរ។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។

- **ការងារឡជីវឧស្ម័ន៖** ដោយមានការអភិវឌ្ឍផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តន៍យ៉ាងសកម្មដែលមកទល់ពេលនេះខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន១០០ឡ (គិតត្រឹមខែមីនា ឆ្នាំ២០១៦)។

- **ការងារដំណាំចំណីសត្វ៖** តាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ធ្វើការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោងអន្តរជាតិដូចជា ACIAR និងCIAT ជាដើម។

**៣.២ ការងារបសុពេទ្យបាល**

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖**

រាជធានី-ខេត្តចំនួន១៧ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន២ ២៦៧លើកនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន៦៧គីឡូក្រាម និងផាកពិន័យជាទឹកប្រាក់បានចំនួន១៥លានរៀល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនជ្រូករស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងរាលដាលនៃជំងឺជ្រូកត្រចៀកខៀវមកពីខេត្តជិតខាង។

- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស។
- **ស្ថិតិសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតនៅទូទាំងប្រទេសសរុបចំនួន១៤១កន្លែង** ដូចមានតារាងខាងក្រោម៖

| ល.រ | ឈ្មោះខេត្ត-ក្រុង | ចំនួនសត្តឃាតដ្ឋាន | | ចំនួនសត្វពិឃាត | | | |
|---|---|---|---|---|---|---|---|
| | | សត្តឃាតដ្ឋានស្របច្បាប់ | ពិឃាតប្រមូលផ្តុំ/ពិឃាតតាមផ្ទះ | គោ (ក្បាល) | ក្របី (ក្បាល) | ជ្រូក (ក្បាល) | មាន់ (ក្បាល) |
| ១ | ភ្នំពេញ | ១១ | | | | | |
| ២ | កណ្តាល | ២២ | | | | | |
| ៣ | កំពង់ស្ពឺ | ១១ | | | | | |

កំផែងសែន៤៣ក្បាល គោកើតថ្មី១ក្បាល គោងាប់២ក្បាល គោលក់២ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប២៣៩ក្បាល ក្នុងនោះជ្រូកបាចំនួន៤ក្បាល ជ្រូកមេ៦៣ក្បាល កូនជ្រូក៩២ក្បាល ជ្រូកថែមថ្មីចំនួន១២ក្បាល មេជ្រូកត្រៀមលក់ចំនួន១៤ក្បាល កូនជ្រូកលក់៤៥ក្បាល និងជ្រូកងាប់ចំនួន៩ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតី និងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៣.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្ដី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្ដាសាយបក្សី និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- បន្តបោះបង្គោលព្រំប្រទល់ព្រៃបម្រុងទុកអចិន្ត្រៃយ៍តាមផែនការសកម្មភាពឆ្នាំ២០១៦ នៅខណ្ឌរដ្ឋបាលព្រៃឈើព្រៃវែង ពោធិ៍សាត់ មណ្ឌលគិរី និងខណ្ឌរដ្ឋបាលព្រៃឈើកំពត

- រៀបចំរបាយការណ៍ការប្រមូលទិន្នន័យធនធានគម្របព្រៃឈើ សម្រាប់ធ្វើការវាយតម្លៃផ្ទៀងផ្ទាត់លទ្ធផលនៃការផលិតផែនទីកាបូនស្តុកព្រៃឈើកម្ពុជា

- ពិនិត្យ និងរៀបចំផែនទីតំបន់សក្ដានុពលសហគមន៍ព្រៃឈើចំនួន១២កន្លែង ដែលមានផ្ទៃដីសរុបចំនួន២ ៩៣៣ហ.ត ក្នុងនោះ៖ ខណ្ឌរដ្ឋបាលព្រៃឈើសៀមរាបចំនួន៨សហគមន៍ ទំហំ១ ៤៤២ហ.ត កំពង់ធំចំនួន១សហគមន៍ ទំហំ២៩៤ហ.ត និងខណ្ឌរដ្ឋបាលព្រៃឈើកណ្ដាលក្នុងខេត្តកំពង់ស្ពឺចំនួន៣សហគមន៍ ទំហំ១ ២៥៧ហ.ត

- កំពុងរៀបចំធ្វើការកែសម្រួលផែនការគ្រប់គ្រងសហគមន៍ព្រៃឈើក្រូចបុង និងសហគមន៍ព្រៃឈើរំដួលថ្មី នៅក្នុងផ្នែករដ្ឋបាលព្រៃឈើកំពង់ស្ពឺនៃខណ្ឌរដ្ឋបាលព្រៃឈើកណ្ដាល

- ផ្ដល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តជូនអតិថិជនសរុបចំនួន ៨គ្រឿង

- ផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន១ ដែលមានឈើហ៊ុបមូលចំនួន៣ ២២៣ម៉ែត្រគ្រីគុណ កូនឈើចំនួន១៥៣ ៨៣២ដើម។

### ៤.២ ការងារអភិរក្សសត្វព្រៃ

- ធ្វើការអង្កេតកត់ត្រាសត្វស្លាបប្រចាំខែនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤ (អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង និងកំពង់ធំ-សៀមរាប) ដោយបានរកឃើញសត្វស្លាបចំនួន២០៦ប្រភេទ ប្រមាណ៩៦ ៩៥២ក្បាល

- ចុះប្រមូលទិន្នន័យ ប្រមូលសំណាកជំងឺសត្វកណ្ដុរដែលស្ថិតនៅភូមិពោធិ៍រោង ឃុំទំរីង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ជាលទ្ធផលប្រមូលបានសំណាកសរុបចំនួន១៦៧សំណាក ពីសត្វកណ្ដុរចំនួន១៤ក្បាល

- ផ្ដល់ចំណីដល់ត្មាតនៅខេត្តស្ទឹងត្រែង ក្រចេះ ព្រៃការពារមណ្ឌលគិរី និងព្រៃការពារព្រះវិហារ ដើម្បីធានាការរស់រានរបស់សត្វត្មាត និងធ្វើការសង្កេតតាមដាន

- ធ្វើការកត់ត្រា និងការពារសម្បុកសត្វរំពេទន្លេចំនួន៦សម្បុក ក្រយ៉ងចង្កំកសចំនួន១សម្បុក នៅខេត្តស្ទឹងត្រែងក្រចេះ ។ ការពារសម្បុកសត្វដើម្បីធានាសុវត្ថិភាពពងកូន ពីព្រោះសម្បុកសត្វទាំងនេះងាយរងគ្រោះដោយសារការប្រមូលរបស់មនុស្ស និងការបំផ្លាញរបស់សត្វព្រៃ ហើយប្រភេទសត្វទាំងនេះជាប្រភេទជិតផុតពូជ ព្រមទាំងចុះអន្តរាគមន៍ជួយដល់ប្រជាពលរដ្ឋដែលទទួលរងការបំផ្លិចបំផ្លាញដោយសត្វដំរីលើផលដំណាំចំនួន៣ករណីដែលមាន៣គ្រួសារ ទទួលរងការខូចខាតផលដំណាំមួយចំនួនរួមមាន ចេកចំនួន៩៩ដើម ស្វាយចំនួន៥ដើម។ ក្រុមអភិរក្សក៏បានចុះសិក្សាស្រាវជ្រាវ និងប្រមូលសំណាកលាមកដំរីនៅជួរភ្នំក្រវាញនៅដំណាក់កាលទី៥ ដោយទទួលបានសំណាកលាមកដំរីចំនួន១៣២សំណាក សម្រាប់យកទៅវិភាគ DNA ដើម្បីកំណត់ចំនួនដំរីព្រៃនៅក្នុងជួរភ្នំក្រវាញ។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែឧសភា ឆ្នាំ២០១៦នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១៤៤ករណី ដោយបញ្ជូនទៅតុលាការចំនួន១២២ករណី និងពិន័យអន្តរការណ៍ចំនួន២២ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៨៩ម៣ ឈើអារចំនួន១៦៨ម៣ ឈើក្រាក់គ្រញូងចំនួន១៩ម៣ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន១១២ក្បាលនិង៥៤២គ.ក្រ អនុផលព្រៃឈើ និងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន២៨៤ហិកតា និងបានដកហូតរណារយន្តចំនួន៣៦គ្រឿង ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រី ការធ្វើអាជីវកម្មត្រូវបានផ្អាកសកម្មភាពចាប់ពីខែមេសារហូតដល់ខែកញ្ញា។ រីឯលទ្ធផលដែលអនុវត្តបានក្នុងរយៈពេល៣ខែដើមឆ្នាំ២០១៦នេះចំនួន១ ០៥០តោន ស្មើនឹង៨,៧៥% នៃផែនការ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១១ ២៣៥តោន

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន២០ ០០០តោន សរុបរយៈពេល៥ខែបានចំនួន១០០ ៨០០តោន ស្មើនឹង២៨,៨០% នៃផែនការ៣៥០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៤៩ ៤៥០តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន៣ ០០០តោន សរុបរយៈពេល៥ខែបានចំនួន២៤ ០០០តោន ស្មើនឹង១៦,០០% នៃផែនការ១៥០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៩ ១៥៥តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន១០ ៥០០តោន សរុបរយៈពេល៥ខែបានចំនួន៤៣ ៣៥០តោន ស្មើនឹង៣៩,៤១% នៃផែនការ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន១១៥តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន១៤ ០០០តោន សរុបរយៈពេល៥ខែបានចំនួន៥៤ ០៥០តោន ស្មើនឹង៣៧,៥៣% នៃផែនការ១៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន៥ ៥០០តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន១៣ ០០០ក្បាល សរុបរយៈពេល៥ខែបានចំនួន៥១ ៣៥០ក្បាល ស្មើនឹង២០,៥៤% នៃផែនការ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន២ ៣៥០ក្បាល

- ការភ្ញាស់កូនត្រីពូជ អនុវត្តបានចំនួនប្រមាណ១២ ០០០ ០០០កូន សរុបរយៈពេល៥ខែបានចំនួន៥០ ០០០ ០០០កូន ស្មើនឹង២៧,៧៨% នៃផែនការ១៨០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥កើនឡើងចំនួនប្រមាណ ៨ ០០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាប អនុវត្តបានចំនួន៣ ០០០តោន សរុបរយៈពេល៥ខែបានចំនួន២២ ៧០០តោន ស្មើនឹង២៧,៦៨% នៃផែនការ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៣ ៨០០តោន

- ផលនេសាទសមុទ្រ អនុវត្តបានចំនួន១ ០៥០តោន សរុបរយៈពេល៥ខែបានចំនួន៤ ៥២៥តោន ស្មើនឹង៥៦,៥៦% នៃផែនការ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន២២៥តោន

- ចូលរួមរៀបចំតាំងពិព័ណ៌លទ្ធផលស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល នៅខេត្តសៀមរាប។

## ៧ ផ្នែកនីតិកម្មកសិកម្ម

### ៧.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន១៨ក្រុមហ៊ុន សរុបចំនួន១៧៩មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន១៣ក្រុមហ៊ុន ត្រូវជា២០ករណី
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មចំនួន០៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន០២ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន០២ក្រុមហ៊ុន។

### ៧.២ ការងារមន្ទីរពិសោធន៍

- ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន០៧ក្រុមហ៊ុន សរុបចំនួន៣៥សំណាក។

### ៧.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម ជូនដល់មន្ទីរកសិកម្មខេត្តប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ និងឧត្តរមានជ័យ
- សហការជាមួយមន្ទីរកសិកម្មខេត្តសៀមរាប និងកំពង់ធំ បើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងធ្វើជាគ្រូឧទ្ទេស ដល់អាជីវករជាអ្នកលក់ដុំ លក់រាយសម្ភារកសិកម្មមានអ្នកចូលរួម១៤១នាក់។

### ៧.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យការនាំចូលរបស់ក្រុមហ៊ុនដែលបានប្រកាសប្រតិវេទន៍អំពីការនាំចូល និងស្នើសុំចុះបញ្ជិកាឃ្លាំងសន្និធិជីកសិកម្ម និងថ្នាំកសិកម្មចំនួន០៩ក្រុមហ៊ុន និង០៩ករណី
- ពិន័យអន្តរការណ៍ជាប្រាក់ចំពោះដេប៉ូឈ្មោះ ចាន់ ថាត នៅខេត្តរតនគិរី។

## ៨ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៣៩៨ច្បាប់ សរុបចំនួន១ ៨០៩ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៣៧៤ច្បាប់ សរុបចំនួន១៦១៣ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន១១១ច្បាប់ សរុបចំនួន៥៥០ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល
- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន១ ០២២ច្បាប់ សរុបចំនួន៤ ១០២ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន៣២ច្បាប់ សរុបចំនួន៣១២ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៤០ច្បាប់ សរុបចំនួន១៩៤ច្បាប់
- សហការរៀបចំប្រមូលថវិកាពីសប្បុរសជនដើម្បីអបអរសាទរខួបលើកទី១៥៣ទិវាកាកបាទក្រហម
- សហការរៀបចំតាំងពិព័រណ៍ផលិតផលកសិកម្មដើម្បីអបអរសាទរព្រះរាជពិធីច្រត់ព្រះនង្គ័លនៅខេត្តសៀមរាប។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦ ៥៦០នាក់ នារីចំនួន១ ៣៨៣នាក់ ស្មើនឹង២១% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន៤ ០២១នាក់ ក្នុងនោះនារីចំនួន៨១៣នាក់ ស្មើនឹង២០%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២ ៥៣៩នាក់ ក្នុងនោះនារីចំនួន៥៧០នាក់ ស្មើនឹង២២%
- ចេញប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌមានចំនួន០២នាក់ ក្នុងនោះបោះបង់ការងារមានចំនួន០១នាក់ និងសុំលាឈប់ពីការងារមានចំនួន០១នាក់

ងារផ្សព្វផ្សាយកសិកម្មនៅពេលអនាគត។ បានចូលរួមសិក្ខាសាលាស្ដីពីការធានាគុណភាពអប់រំនៅថ្នាក់ឧត្ដម បញ្ហាប្រឈម និងទិសដៅការងារ។ បានចូលរួមប្រជុំការងារស្ដង់ដារ ដើម្បីរៀបចំសេចក្ដីព្រាងស្ដង់ដារអង្ករផ្កាម្លិះ និងផ្កាច័ន្ទសែនសរ នៅវិទ្យាស្ថានស្ដង់ដារអង្ករកម្ពុជា។ មន្ត្រីជំនាញ០២រូប បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី Food processing and Preservation Technology for the Kingdom of Cambodia នៅប្រទេសចិន។

## ១១.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥-២០១៦ សរុបមានចំនួន៩០៨នាក់(ស្ត្រី៣៧០នាក់) រួមមាន៖

- និស្សិតអាហារូបករណ៍សរុប៨៥៩នាក់ (ស្ត្រី៣៥៤នាក់) ក្នុងនោះថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មចំនួន៨៥៥នាក់(ស្ត្រី១៧៨នាក់) និងថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មចំនួន១២៥នាក់(ស្ត្រី៥១នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃចំនួន៤៩នាក់ (ស្ត្រី១៦នាក់) ថ្នាក់បរិញ្ញាបត្រចំនួន៣៨នាក់(ស្ត្រី១៥នាក់) និងថ្នាក់បរិញ្ញាបត្ររងចំនួន១១នាក់ (ស្ត្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានបញ្ជូននិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ ទាំង៥ជំនាញឲ្យចុះទំនាក់ទំនងធ្វើកម្មសិក្សា ចងក្រងសារណាបទបញ្ចប់ការសិក្សានៅតាមមូលដ្ឋាន តាមមន្ទីរ ស្ថាប័នរដ្ឋ និងតាមបណ្ដាអង្គការនានា ព្រមទាំងចុះធ្វើការពិសោធន៍ស្រាវជ្រាវលើទីវាលតាមមុខជំនាញនីមួយៗផងដែរ។ សាលាបានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីកៀរគររកជំនួយ ក្នុងនោះកំពុងសហការជាមួយអង្គការពេទ្យសត្វគ្មានព្រំដែនដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្ដុះបណ្ដាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ ព្រមទាំងបានទទួលជួបតំណាង JICA ដើម្បីពិភាក្សាពីគម្រោងកសិកម្មជីសិរីរាង្គ និងកំពុងព្រាងគម្រោងស្រាវជ្រាវ។

## ១១.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥ សរុបមានចំនួន៣ ៩២៤នាក់(ស្ត្រី១ ១៨៧នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងថ្នាក់ក្រោយឧត្ដម ដើម្បីបណ្ដុះបណ្ដាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យបានបញ្ជូននិស្សិតចុះធ្វើទស្សនកិច្ចសិក្សា និងធ្វើកម្មសិក្សាអនុវត្តន៍ជាក់ស្ដែងនៅតាមសហគមន៍និងមូលដ្ឋានផលិតកម្មនានា ក្នុងនោះមហាវិទ្យាល័យវេជ្ជសាស្ត្រសត្វបានបញ្ជូននិស្សិតចំនួន ៣០០នាក់ទៅខេត្តសៀមរាប និងមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទចំនួន២០០នាក់ទៅខេត្តកំពត។ និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្មបានទទួលបដិសណ្ឋារកិច្ចបវរកញ្ញាសាកលឆ្នាំ២០១៥ ដែលមានដើមកំណើតខ្មែរ មកទស្សនកិច្ចក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងចូលរួមកម្មវិធីសង្គមជាមួយនិស្សិតកម្មសិក្សានៅខេត្តសៀមរាប។ សាកលវិទ្យាល័យនិងក្រុមហ៊ុន Agrostudies បានរៀបចំពិធីសំណេះសំណាលជាមួយនិស្សិតចំនួន១៥០នាក់ ដែលត្រៀមខ្លួនចូលរួមធ្វើកម្មសិក្សានៅប្រទេសអ៊ីស្រាអែល រយៈពេល១១ខែ ក្នុងឆ្នាំសិក្សា២០១៦-២០១៧ ខាងមុខនេះ ។ ថ្នាក់ដឹកនាំ មន្ត្រីសាស្ត្រាចារ្យ និងនិស្សិតបញ្ចប់កម្មសិក្សាពីអ៊ីស្រាអែល បានចូលរួមប្រជុំជាមួយឯកអគ្គរដ្ឋទូតអ៊ីស្រាអែល ដើម្បីពិភាក្សាអំពីលទ្ធផលទទួលបានពីកម្មវិធីកម្មសិក្សា នៅអ៊ីស្រាអែល និងអំពីការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការបន្ថែម រវាងសាកលវិទ្យាល័យ និងក្រុមហ៊ុន Agrostudies។ សាកលវិទ្យាល័យបានសហការជាមួយសមាគម Ago-Smart ធ្វើសិក្ខាសាលា ស្ដីពីការប្រើប្រាស់ឧបករណ៍ដាំស្រូវ និងឧបករណ៍ស្រោចស្រព ជូនដល់និស្សិតមហាវិទ្យាល័យវិស្វកម្មកសិកម្ម ព្រមទាំងបានប្រជុំពិភាក្សាជាមួយភាគីសាកលវិទ្យាល័យហាណូយ និង អង្គការGIZ របស់អាល្លឺម៉ង់ ដើម្បីបង្កើតកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាជាន់ខ្ពស់អន្តរជាតិជំនាញព្រៃឈើតំបន់ត្រូពិច។

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចនិងផ្តល់ក្តីសង្ឃឹមអំពីតម្លៃកៅស៊ូនៅលើទីផ្សារដែលអាចនឹងឡើងថ្លៃវិញនៅពេលអនាគត។

**២ ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺជ្រូកគ្រុនចៀកខៀវ ក៏ដូចជាជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល

- បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋាន។

**៣ ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និង

នឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀប និងកំពង់ចាមឱ្យទៅជាវិទ្យាស្ថានវិញ

- បន្តរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា តាមស្មារតីនៃលិខិតលេខ១៣០៣ សជណ.សរ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

- បន្តសហការអនុវត្តអនុក្រឹត្យលេខ៣៤អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទី និងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ការពារនិងអភិរក្សព្រៃឈើនិងជលផល ជាពិសេសការផ្ទេរតំបន់ព្រៃការពារ តំបន់អភិរក្សព្រៃឈើចំនួន១៣កន្លែង និងព្រៃផ្តល់ផលចំនួន៥កន្លែង ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រសួងបរិស្ថានគ្រប់គ្រង និងបានផ្ទេរតំបន់សម្បទានដីសេដ្ឋកិច្ចចំនួន៧៣កន្លែង ពីក្រសួងបរិស្ថាន ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់គ្រងបន្ត តាមរយៈអនុក្រឹតលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៦

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ គោលការណ៍ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្ម មានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស និងការផលិតសម្រាប់ឈានទៅរកការធ្វើសមាហរណកម្មពាណិជ្ជកម្មផលិតផលកសិកម្មក្នុងបរិបទនៃសាកលភាវូបនីយកម្ម។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**